ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

Kingdom of Wonder

ក្រសួងទេសចរណ៍

លេខ ១១១ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ៦ ឆ្នាំ២០១១

# ប្រកាស
# ស្តីពី
# ការរៀបចំស្ថិតិទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១._**

ប្រកាសនេះ មានគោលបំណងណែនាំនូវវិធាន វិធីសាស្រ្ត និងកំណត់និយមន័យនៃពាក្យស័ព្ទមួយចំនួនដែលចាំបាច់ក្នុងការប្រមូល ចងក្រងទិន្នន័យស្ថិតិទេសចរណ៍ ដើម្បីបម្រើដល់ការចង្អុលបង្ហាញសូចនាករស្ថិតិទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្ទះលេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website:www.mot.gov.kh

**ប្រការ ២._**

ការរៀបចំស្ថិតិទេសចរណ៍ ត្រូវធ្វើឡើងស្របតាមនិយមន័យ វិធីសាស្ត្រ និងស្តង់ដាស្ថិតិ ដោយឈរលើមូលដ្ឋាននៃគោលការណ៍ភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសត្យានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាពទាន់ពេលវេលា។

**ប្រការ ៣._**

វាក្យស័ព្ទចាំបាច់មួយចំនួន ដែលបម្រើដល់ការរៀបចំស្ថិតិទេសចរណ៍ ត្រូវបានកំណត់ដូចខាងក្រោម៖

ក. ស្ថិតិ គឺជាទិន្នន័យដែលបានមកដោយការប្រមូល ការរៀបចំ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយលទ្ធផលនៃចម្លើយតាមការប្រមូលស្ថិតិ ឬពីប្រភពទិន្នន័យរដ្ឋបាល។

ខ. ទិន្នន័យ គឺជាព័ត៌មានដែលមានរូបភាពជាតួលេខ។

គ. ស្ថិតិទេសចរណ៍ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង ដែលផលិតដោយក្រសួងទេសចរណ៍។

ឃ. ទេសចរណ៍ (Tourism) សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គល ដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលកំណត់មួយ ដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នា ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។

ង. ទេសចរ (Tourist) សំដៅដល់បុគ្គលទាំងឡាយជាជនជាតិកម្ពុជា ឬជនបរទេស ដែលមកពីតំបន់ផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះ។

ច. ទេសចរជាតិ សំដៅដល់ទេសចរជាជនជាតិកម្ពុជា ដែលបានធ្វើដំណើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។

ឆ. ទេសចរអន្តរជាតិ សំដៅដល់ទេសចរជាជនបរទេស ដែលមកទស្សនាព្រះរាជាណាចក្រកម្ពុជា ។

ជ. ទេសចរអន្តរជាតិផ្ទៃក្នុង សំដៅដល់ជនបរទេសទាំងឡាយ ដែលបានស្នាក់នៅស្របច្បាប់ ហើយបានធ្វើដំណើរដើម្បីសម្រាកលំហែ កម្សាន្ត និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា។

ឈ. ទេសចរកម្ពុជាចេញក្រៅប្រទេស សំដៅដល់ជនជាតិកម្ពុជា ដែលបានធ្វើដំណើរចេញពីព្រះរាជាណាចក្រកម្ពុជាទៅបរទេស ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។

ញ. អ្នកធ្វើដំណើរកម្សាន្ត (Same-day visitor) សំដៅដល់បុគ្គលទាំងឡាយ ជាជនជាតិកម្ពុជា ឬ ជនបរទេស ដែលធ្វើដំណើរទៅកាន់តំបន់ណាមួយ ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងធ្វើសកម្មភាពទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ក្នុងអំឡុងពេលតិចជាងមួយយប់។

ដ. អង្កេតទេសចរណ៍ គឺជាការប្រមូលទិន្នន័យតាមបែបវិទ្យាសាស្ត្រពីទេសចរជាតិ ឬទេសចរអន្តរជាតិ ដែលអង្គភាពស្ថិតិជ្រើសរើសជាគំរូ។

ឋ. កម្លាំងពលកម្មបម្រើឲ្យវិស័យទេសចរណ៍ សំដៅដល់ជនទាំងឡាយណា ដែលបាន និងកំពុងបម្រើការងារដោយផ្ទាល់ក្នុងវិស័យទេសចរណ៍។

ឌ. កម្លាំងពលកម្មជំនាញទេសចរណ៍ សំដៅដល់ជនទាំងឡាយណា ដែលមានជំនាញផ្នែកទេសចរណ៍ និងកំពុងបម្រើការងារដោយផ្ទាល់ក្នុងវិស័យទេសចរណ៍។

**ប្រការ ៤._**

ស្ថិតិទេសចរណ៍ ត្រូវបានប្រមូល រៀបចំ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយលទ្ធផលជាផ្លូវការ ដែលត្រូវរៀបចំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍។

**ប្រការ ៥._**

នាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ ជាអង្គភាពស្ថិតិនៃក្រសួងទេសចរណ៍ មានភារកិច្ចទទួលខុសត្រូវក្នុងការ ៖

- ប្រមូល រៀបចំ ចងក្រង វិភាគ ព្យាករណ៍ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យគ្រឹះតាមរយៈការធ្វើអង្កេតទេសចរណ៍ និងប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល។
- ចងក្រងគណនីរណបទេសចរណ៍ (Tourism Satellite Account - TSA) និងសូចនាករទេសចរណ៍ផ្សេងទៀត។

**ប្រការ ៦._**

មន្ទីរទេសចរណ៍រាជធានី-ខេត្ត អង្គភាពពាក់ព័ន្ធ និងប្រតិបត្តិករទេសចរណ៍ត្រូវប្រមូលទិន្នន័យប្រចាំខែតាមផ្នែកនីមួយៗ និងផ្ញើមកនាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍ ឲ្យបាននៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ដើម្បីធានាបាននូវគោលការណ៍នៃភាពទាន់ពេលវេលា។

**ប្រការ ៧._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨._**

អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានអធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ប្រតិបត្តិករទេសចរណ៍ទាំងអស់ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- វិទ្យាស្ថានជាតិស្ថិតិ
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ